

# ការធ្វើជាកម្មសិទ្ធិ ដែលមានស្ថិរភាព ហើយសមរម្យ

## គំរោងរៀនសូត្រសំរាប់កុមារវ័យដំបូង សំរាប់ប្រទេសអូស្ត្រាលី





BELONGING,
BEING &
BECOMING

An Early Years Learning Framework for Australia

ព័ត៌មានសំរាប់គ្រួសារ

Khmer

# គំរោងរៀនសូត្រ សំរាប់កុមារវ័យដំបូង

## គំរោងរៀនសូត្រជាតិថ្មីមួយសំរាប់កុមារវ័យដំបូង ដែលមានអាយុចាប់ពីកំណើត ទៅ៥ឆ្នាំ

### តើគំរោងរៀនសូត្រថ្មីនេះគឺអំពីអ្វី?

យើងបានបង្កើតឲ្យមានគំរោងរៀនសូត្រសំរាប់កុមារវ័យដំបូងដើម្បីឲ្យបានច្បាស់ប្រាកដថា កូនរបស់លោកអ្នកទទួលបាននូវកម្មវិធីអប់រំដែលមានគុណភាពនៅកន្លែងកុមារភាពវ័យដំបូងរបស់គេ។ នេះគឺជាពេលមួយដែលមានសារសំខាន់បំផុត ដើម្បីឲ្យគេអាចរៀនសូត្រ ហើយរីកចំរើន។

ទស្សនះរបស់គំរោងគឺសំរាប់ក្មេងទាំងអស់ ដើម្បីទទួលបទពិសោធន៍លើការរៀនសូត្រដែលមានការទាក់ទិន ហើយសាងសង់លើជោគជ័យសំរាប់ជីវិតរស់នៅ។



នេះគឺជាការណែនាំសំរាប់អ្នកអប់រំកុមារភាពវ័យដំបូង ដែលធ្វើការជាមួយកុមារអាយុចាប់ពីកំណើត ទៅ៥ឆ្នាំ។ គេនឹងប្រើគំរោងនេះដោយរួមដៃគ្នាជាមួយគ្រួសារ ជាអ្នកអប់រំកុមារទីមួយ ហើយមានឥទ្ធិពលជាទីបំផុត ដើម្បីបង្កើតកម្មវិធីរៀនសូត្រដែលឆ្លើយតបភ្លាមៗទៅនឹងគំនិត ការចូលចិត្ត កម្លាំង និងសមត្ថភាពរបស់កុមារ ហើយទទួលស្គាល់ថាកុមាររៀនចេះតាមរយៈការលេងរបស់គេ។

គំរោងរៀនសូត្រសំរាប់កុមារវ័យដំបូង ផ្តល់អត្ថន័យកុមារភាពថាជាពេលនៃ*ការធ្វើជាកម្មសិទ្ធិ* *ដែលមានស្ថិរភាព* ហើយ*សមរម្យ*។

- **ដែលជាកម្មសិទ្ធិ** គឺជាមូលដ្ឋានសំរាប់ការរស់នៅក្នុងជីវិតដែលបំពេញ។ កុមារមានអារម្មណ៍ថាគេ*ធ្វើជាកម្មសិទ្ធិ* ដោយព្រោះទំនាក់ទំនងដែលគេមានជាមួយគ្រួសាររបស់គេ សហគមន៍ វប្បធម៌ ហើយនិងទីកន្លែង។
- **ដែលមានស្ថិរភាព** គឺអំពីការរស់នៅទីនេះ ហើយក្នុងពេលឥឡូវនេះ។ កុមារភាពគឺជាពេលដ៏ពិសេសមួយក្នុងជីវិត ហើយកុមារត្រូវការពេលដើម្បីគ្រាន់តែឲ្យមាន ‘ស្ថិរភាព’ - ដើម្បីលេងសាកល្បងកិច្ចការថ្មីៗ ហើយលេងកំសាន្ត។
- **ដែលសមរម្យ** គឺអំពីការរៀនសូត្រ និងការរីកចំរើនដែលកុមារតូចៗមានបទពិសោធន៍។ កុមារចាប់ផ្តើមបង្កើតនូវការដឹងយល់ពីអត្តសញ្ញាណរបស់គេចាប់ពីអាយុនៅតូចម្ល៉េះ ដែលឲ្យគេលេចចេញជាប្រភេទនៃមនុស្សជំទង់ ដែលគេនឹងក្លាយទៅជាមនុស្សមួយរូបដែលសមរម្យ។



“ខ្ញុំចង់ឲ្យកូនរបស់ខ្ញុំមានឱកាសយ៉ាងច្រើនដើម្បីលេងដែលប្រកបទៅដោយការឆ្នៃប្រឌិត”

## ការលេងគឺជាការរៀនសូត្រ

ការលេងគឺមានសារសំខាន់ណាស់សំរាប់កុមារចាប់ពីកំណើតភ្លាមមក។ តាមរយៈការលេង ទារក និងកុមារតូចៗរុករក ហើយរៀនដើម្បីឲ្យមានការដឹងយល់អំពីពិភពនៅជុំវិញគេ ក្នុងកាលគេចាប់ផ្ដើមធ្វើការទាក់ទង រកឃើញ ប្រមើលមើល ហើយចេះបង្កើត។

ពេលណាកុមារលេង គេបង្ហាញប្រាប់អំពីអ្វីដែលគេបានរៀនចេះ និងអំពីអ្វីដែលគេសាកល្បងដើម្បីឲ្យបានយល់។ ហេតុនេះហើយការលេងគឺជាគ្រឹះមួយក្នុងចំណោមគ្រឹះឯទៀតនៃគំរោងរៀនសូត្រសំរាប់កុមារវ័យដំបូង។

ដោយសារការប្រើគំរោងនេះ អ្នកអប់រំនឹងណែនាំការលេងរបស់កូនលោកអ្នក ដោយរៀបគ្រោងឲ្យមានសកម្មភាពរៀនសូត្រដោយយកចិត្តទុកដាក់ ហើយជួយជំរុញដល់បរិស្ថានរៀនសូត្រមាននៅក្រៅអាគារ និងក្នុងអាគារ។

## ទំនាក់ទំនង<br>គឺជាគន្លឹះដ៏សំខាន់



នេះត្រូវបានគេស្គាល់ថា កុមាររៀនល្អបំផុតពេលណាគេមានទំនាក់ទំនងរឹងមាំជាមួយមនុស្សជំទង់ដែលចេះយកចិត្តទុកដាក់ចំពោះគេ។ ពេលណាកុមារចាប់ពីអាយុនៅតូចបង្កើតទំនាក់ទំនងការទុកចិត្ត នោះគេមានអារម្មណ៍ទុកចិត្តកាន់តែច្រើនឡើង ហើយអាចចាប់រុករក ហើយរៀនសូត្រ។

នៅកន្លែងកុមារភាពវ័យដំបូង ពេលណាកុមារមានអារម្មណ៍ខាងផ្លូវចិត្តរឹងមាំល្អ នោះគេអាចបង្កើតជំនាញការ និងការដឹងយល់ដែលគេត្រូវការ ដើម្បីប្រាស្រ័យទាក់ទងដោយវិជ្ជមានជាមួយមនុស្សឯទៀត ហើយក្រោយៗមកក៏ចាប់ផ្ដើមរៀនទទួលខុសត្រូវ។

# តើវានឹងមាន ដំណើរការដូចម្តេច?

អ្នកអប់រំនឹងប្រើគំរោងថ្មីនេះនៅតាមកន្លែងកុមារភាពវ័យដំបូងមួយចំនួន មានរួមទាំងកន្លែងមើលថែពេញមួយថ្ងៃ សាលាថ្នាក់ត្រៀម និងកន្លែងមើលថែគ្រួសារពេលថ្ងៃ ដើម្បីប្រាកដឲ្យបានច្បាស់ថាកូនរបស់លោកអ្នក បានទទួលបទពិសោធន៍ដែលមានគុណភាពខ្ពស់។ គំរោងនេះត្រូវបានបង្កើតឡើង ហើយសាកល្បងមើលដោយអ្នកអប់រំកុមារភាពវ័យដំបូងដែលមានបទពិសោធន៍ និស្សិត មាតាបិតា និងអ្នកមើលថែ។

“លទ្ធផលនៃការរៀនសូត្រគឺល្អ ហើយជួយខ្ញុំឲ្យចេះគិតអំពីបែបយ៉ាងណាដែលកូនរបស់ខ្ញុំកំពុងរីកចំរើន”

គំរោងផ្តោតទៅលើការរៀនសូត្ររបស់កូនលោកអ្នក។ អ្នកអប់រំនឹងធ្វើការជាមួយលោកអ្នក ក្នុងគោលបំណងដើម្បីឲ្យបានស្គាល់កូនរបស់លោកអ្នកកាន់តែច្បាស់ឡើង។ គេនឹងបង្កើតកម្មវិធីរៀនសូត្រមួយដែលសាងសង់លើចំណង់ចូលចិត្ត និងសមត្ថភាពរបស់កូនលោកអ្នក ហើយរក្សាលោកអ្នកឲ្យបានដឹងពីដំណើរជឿនលឿនទៅមុខរបស់កូនលោកអ្នក។

តាមរយៈគោលដៅរៀនសូត្រទាំងប្រាំរបស់គំរោង អ្នកអប់រំនឹងជួយកូនរបស់លោកអ្នកបង្កើតៈ

- ការដឹងយល់យ៉ាងរឹងមាំអំពីអត្តសញ្ញាណរបស់គេ
- ការតភ្ជាប់ជាមួយនឹងពិភពរបស់គេ
- ការដឹងយល់យ៉ាងរឹងមាំអំពីសុខុមាលភាពរបស់គេ
- ការទុកចិត្ត និងការទាក់ទិននៅក្នុងការរៀនសូត្ររបស់គេ ហើយនិង
- ជំនាញការទាក់ទងដែលមានប្រសិទ្ធិភាព។






# ការឃ្លាំមើលដំណើរជឿនលឿនទៅមុខរបស់កូនលោកអ្នក

ដោយសារការប្រើគំរោងរៀនសូត្រសំរាប់កុមារវ័យដំបូង អ្នកអប់រំនឹងពិនិត្យឃ្លាំមើលការរៀនសូត្ររបស់កូនលោកអ្នក ដើម្បីឲ្យគេអាចសាងសង់ពីលើវា ហើយរៀបគ្រោងជំហានបន្ទាប់ទៀត។ គេនឹងធ្វើការនេះដោយការស្តាប់ ការឃ្លាំមើល ហើយនិងការនិយាយទៅកាន់កូនរបស់លោកអ្នក។

គេនឹងរក្សាការទាក់ទងជាមួយលោកអ្នកយ៉ាងទៀងទាត់ ដើម្បីពិភាក្សាអំពីដំណើរជឿនលឿនទៅមុខរបស់កូនលោកអ្នក។ គេប្រហែលជាត្រូវប្រើរូបថត ឬរក្សាក្របដាក់កិច្ចការរបស់កូនលោកអ្នក ដើម្បីបង្ហាញប្រាប់ពីអ្វីៗដែលកូនរបស់លោកអ្នកកំពុងរៀន របៀបយ៉ាងណាដែលគេកំពុងរីកចំរើន ហើយនិងអ្វីដែលគេចូលចិត្ត។

មុនពេលកូនរបស់លោកអ្នកចាប់ផ្តើមចូលរៀន អ្នកអប់រំនឹងរៀបចំព័ត៌មានអំពីការរៀនសូត្រ និងការរីកចំរើនរបស់កូនលោកអ្នក ដើម្បីចែកចាយជាមួយគ្រូបង្រៀនថ្មីរបស់គេ។ ការនេះនឹងជួយប្រាកដឲ្យបានច្បាស់ថា សាលារៀនថ្មីរបស់កូនលោកអ្នករៀបចំប្រុងប្រៀបបានល្អដើម្បីបន្តការរៀនសូត្ររបស់កូនលោកអ្នក។

“គំរោងរៀនសូត្រសំរាប់កុមារវ័យដំបូងជួយខ្ញុំឲ្យបានយល់អំពីជំនាញការបែបណាដែលបុគ្គលិកនៅតាមមជ្ឈមណ្ឌលរបស់ខ្ញុំមាន ហើយថាការផ្គត់ផ្គង់យ៉ាងប្រសើរដែលគេមានចំពោះខ្ញុំនិងគ្រួសាររបស់ខ្ញុំ។”

# ធ្វើការរួមគ្នា

ដោយសារការធ្វើការរួមគ្នា មាតាបិតា និងអ្នកអប់រំអាចលើកស្ទួយការរៀនសូត្រ និងសុខុមាលភាពរបស់កុមារឲ្យបានរឹតកាន់តែល្អប្រសើរឡើង។

ក្នុងភាពជាជនដ៏សំខាន់ជាងគេម្នាក់នៅក្នុងជីវិតរបស់កូនលោកអ្នក លោកអ្នកអាចធ្វើឲ្យមានការខុសផ្លែក ដោយនិយាយឲ្យបានទៀងទាត់ជាមួយអ្នកអប់រំកុមារភាពវ័យដំបូងរបស់កូនលោកអ្នក ហើយបង្ហាញឲ្យឃើញអំពីការចូលចិត្តរបស់លោកអ្នក នៅក្នុងការរៀនសូត្ររបស់គេ។

ព័ត៌មានដែលលោកអ្នកផ្តល់ អនុញ្ញាតឲ្យអ្នកអប់រំតភ្ជាប់បទពិសោធន៍របស់កូនលោកអ្នកនៅផ្ទះ ជាមួយនឹងពេលវេលាដែលគេចំណាយជាមួយគ្នានៅកន្លែងកុមារភាពវ័យដំបូង។





# ទទួលព័ត៌មានច្រើនថែមទៀត

កូនសៀវភៅនេះគឺជាការណែនាំទៅនឹងគំរោងរៀនសូត្រសំរាប់កុមារវ័យដំបូង។

ដើម្បីឲ្យបានដឹងច្រើនថែមទៀត  សូមបើកមើលវិបសាយ: deewr.gov.au/earlychildhood
ឬសាកសួរអ្នកអប់រំកុមារភាពវ័យដំបូងរបស់កូនលោកអ្នក។

Produced by the Australian Government Department of Education, Employment and Workplace Relations for the Council of Australian Governments.

A09-057



